# សេចក្តីអញ្ជើញចូលរួមសវនាការអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក
# ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨

អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានកំណត់ពេលបើកសវនាការសាធារណៈនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨។ អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យស្ថានីយ៍វិទ្យុ និងទូរទស្សន៍ផ្សាយផ្ទាល់នូវកិច្ចដំណើរការនីតិវិធីជូនសាធារណជន។ តំណាងប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនទូទៅក៏ត្រូវបានអញ្ជើញឱ្យចូលរួមដោយផ្ទាល់ផងដែរ។

សវនាការនឹងចាប់ផ្តើមនៅវេលាម៉ោង ៩:៣០នាទីព្រឹក ថ្ងៃទី៤ ខែកុម្ភៈ ហើយនៅពេលនោះចៅក្រមនឹងកំណត់ថ្ងៃសវនាការជាបន្តបន្ទាប់។ សាធារណជនទាំងអស់ត្រូវអង្គុយនៅតាមទីតាំងកំណត់ ៣០នាទីមុនពេលបើកសវនាការ។ នៅថ្ងៃទី៤ ខែកុម្ភៈ សូមសាធារណជនមកដល់នៅចន្លោះម៉ោង ៨.០០ ដល់ ៨.៣០ ព្រឹក ដើម្បីទុកពេលគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យសុវត្ថិភាព និងទទួលបណ្ណអនុញ្ញាតចូលរួម។ ច្រកទ្វារចេញចូល នឹងបិទនៅម៉ោង ០៩:០០ ព្រឹក ឬ នៅពេលដែលកៅអីទាំងអស់នៅក្នុងបន្ទប់សវនាការពេញអស់។

សាធារណជនទាំងអស់ដែលមានបំណងចូលតាមដានសវនាការនៅ អ.វ.ត.ក ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ (រួមទាំងរូបថត) ហើយត្រូវឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យសុវត្ថិភាព។ សូមបញ្ជាក់ថា កុមារអាយុក្រោម ១៨ឆ្នាំ មិនត្រូវអនុញ្ញាតឲ្យចូលបន្ទប់សវនាការនោះឡើយ។ ហាមយកទូរស័ព្ទដៃ សម្ពាយធំៗ អាហារ ឬ ភេសជ្ជៈចូលបន្ទប់សវនាការ។

កន្លែងអង្គុយក្នុងបន្ទប់សវនាការធំត្រូវបានបែងចែកដូចខាងក្រោម៖

**ប្រព័ន្ធផ្សព្វផ្សាយ** - ត្រូវចុះឈ្មោះជាមុន។ កាលបរិច្ឆេទផុតកំណត់ថ្ងៃទី៣១ ខែមករា ម៉ោង ៥ល្ងាច។ ប្រសិនបើកៅអីទាំងនេះមិនត្រូវបានប្រើប្រាស់ទាំងអស់ត្រឹមម៉ោង ១០ព្រឹក នៅថ្ងៃសវនាការនោះទេ កៅអីទាំងនោះនឹងផ្តល់ជូនសាធារណជនទូទៅ។ សម្រាប់ព័ត៌មានលម្អិតនៃការចេញ-ចូលសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងគ្រឿងបរិក្ខារ សូមមើលបណ្ណព័ត៌មានដោយឡែកសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ឬ ទូរស័ព្ទទាក់ទងលោក ម៉ៅ វុត្ថា តាមរយៈលេខ ០២៣ ២១៩៨១៤ លេខតភ្ជាប់ ៦១៦៦ ឬ ០១១ ៣៦៤៤៤៤ ឬ អ៊ីម៉ែល៖ mao.vutha@eccc.gov.kh។

**តំណាងអង្គការមិនមែនរដ្ឋាភិបាល** - ៥០ កៅអី សម្រាប់តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ (ច្រើនបំផុត ០២រូបក្នុងមួយអង្គការ) ដោយតម្រូវឲ្យចុះឈ្មោះជាមុន។ កាលបរិច្ឆេទផុតកំណត់ថ្ងៃទី៣១ ខែមករា ម៉ោង ៥ល្ងាច។ ប្រសិនបើកៅអីទាំងនេះមិនត្រូវបានប្រើប្រាស់អស់ត្រឹមម៉ោង ១០ ព្រឹក នៅថ្ងៃបើកសវនាការ នោះនឹងប្រគល់ជូនសាធារណជន។ ការចូលតាមច្រកកាត់នឹងផ្តល់ជូនសម្រាប់អ្នកដែលផ្ត

Original EN: 01699274-01699275

ល់ឈ្មោះជូនយើងរួចរាល់ជាមុន។ សូមទំនាក់ទំនង ជិន ហែមវិចិត្រ តាមរយៈ (០២៣) ២១៩៨១៤ លេខតភ្ជាប់ ៦០៦៥ ឬ (០១២) ៦៩៦២២០ ឬ អ៊ីមែល info@eccc.gov.kh។

**ក្រុម** - ១៤០កៅអី សម្រាប់ក្រុម (អតិបរមា ២០នាក់ក្នុងមួយក្រុម) ដោយតម្រូវឲ្យចុះឈ្មោះជាមុន។ កាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី៣១ ខែមករា វេលាម៉ោង ៥ល្ងាច។ ប្រសិនបើកៅអីទាំងនេះមិនត្រូវបានប្រើប្រាស់អស់ត្រឹមម៉ោង១០ព្រឹកនៃថ្ងៃបើកសវនាការ នឹងត្រូវចាត់ចែងជូនសាធារណជនទូទៅ។

ការចូលតាមច្រកកាត់នឹងផ្តល់ជូន លោក-អ្នក ដែលបានផ្តល់ឈ្មោះមកមុន។ សូមទាក់ទង លោក ជិន ហែមវិចិត្រ តាមរយៈលេខទូរសព្ទ (០២៣) ២១៩៨១៤ លេខតំណភ្ជាប់ ៦០៦៥ ឬ (០១២) ៦៩៦២២០ ឬអ៊ីមែល info@eccc.gov.kh។

**សាធារណជនទូទៅ** ត្រូវបានលើកទឹកចិត្តឱ្យចុះឈ្មោះជាមុន នឹងផ្តល់ទីតាំងអង្គុយចំនួន ១០០កន្លែងទៅតាមលំដាប់លំដោយអ្នកមកមុនបានមុន។ ការចូលតាមច្រកកាត់នឹងផ្តល់ជូនលោក-អ្នកដែលបានផ្តល់ឈ្មោះមកមុន។ លោកអ្នកចាំបាច់ត្រូវចុះឈ្មោះមុន ប្រសិនបើចង់ប្រើប្រាស់សេវារថយន្តក្រុងឥតគិតថ្លៃរបស់ អ.វ.ត.ក (សូមមើលខាងក្រោម)។

**ការដឹកជញ្ជូន** - អ.វ.ត.ក នឹងផ្តល់សេវារថយន្តក្រុងដោយឥតគិតថ្លៃសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនដែលមិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនពីរាជធានីភ្នំពេញទៅកាន់ អ.វ.ត.ក និងត្រឡប់មកវិញ។ រថយន្តក្រុងនឹងចេញដំណើរពីមុខស្ថានីយ៍រថភ្លើងភ្នំពេញចន្លោះពីម៉ោង ៧.៣០ ដល់ ៨.០០ព្រឹករៀងរាល់ថ្ងៃសវនាការ។ លោកអ្នកតម្រូវឲ្យចុះឈ្មោះជាមុន។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងនៅសង្កាត់ចោមចៅ ចម្ងាយប្រមាណ ១៦ គីឡូម៉ែត្រ ពីភ្នំពេញ នៅខាងឆ្វេងដៃ ផ្លូវជាតិលេខ ៤។ សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយ សូមចូលតាមច្រកទ្វារសម្រាប់ភ្ញៀវនៅច្រកខាងកើតនៃបរិវេណតុលាការ។

**គ្រឿងបរិក្ខារ** - ទឹកពិសានឹងផ្តល់ជូននៅក្នុងសាលធំនៅខាងក្រៅបន្ទប់សវនាការ។ លោក-អ្នក មិនត្រូវបានអនុញ្ញាតឱ្យយកអាហារ ឬភេសជ្ជៈចូលបន្ទប់សវនាការនោះទេ។ អាហារនឹងមានលក់នៅខាងក្រៅ។

បង្គន់អនាម័យមានផ្តល់ជូននៅក្នុងអគារតុលាការ និងចំណតរថយន្ត។

កន្លែងចតរថយន្តនឹងត្រូវបានផ្តល់ជូនសម្រាប់ភ្ញៀវដែលអញ្ជើញមក អ.វ.ត.ក តាមរថយន្តក្រុង ឬ រថយន្តផ្ទាល់ខ្លួន។

មានការផ្តល់ជំនួយជូនដល់ជនពិការ រួមទាំងជម្រាលសម្រាប់រទេះជនពិការ។

Original EN: 01699274-01699275

ដើម្បីចុះឈ្មោះសម្រាប់កន្លែងអង្គុយ និងការដឹកជញ្ជូន សូមទាក់ទង ជិន ហែមវិចិត្រ តាមព័ត៌មានដូចខាងក្រោម៖

អ៊ីមែល៖ info@eccc.gov.kh

ទូរស័ព្ទ៖ (០២៣) ២១៩៨១៤ លេខតំណភ្ជាប់ ៦០៦៥ ឬ (០១២) ៦៩៦២២០

ទូរសារ៖ (០២៣) ២១៩៨៤១

Original EN: 01699274-01699275